អង្គភាពសវនកម្មផ្ទៃក្នុង
INTERNAL AUDIT UNIT

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញ
# ស្តីពី
# ការវាយតម្លៃអំពីប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃផែនការសវនកម្ម សម្រាប់ឆ្នាំ២០២២

ដោយលោក អ៊ឹម សុផល ប្រធាននាយកដ្ឋានសវនកម្មទី២

ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២

# មាតិកា


១ បញ្ហាប្រឈម និងដំណោះស្រាយ៖ ដំណាក់កាលចុះស្វែងយល់សវនដ្ឋាន

២ បញ្ហាប្រឈម និងដំណោះស្រាយ៖ ដំណាក់កាលរៀបចំផែនការសវនកម្មអនុលោមភាពឆ្នាំ២០២២

៣ បញ្ហាប្រឈម និងដំណោះស្រាយ៖ ដំណាក់កាលចុះប្រមូលទិន្នន័យ និងព័ត៌មាននៅសវនដ្ឋាន

៤ បញ្ហាប្រឈម និងដំណោះស្រាយ៖ ដំណាក់កាលរៀបចំរបាយការណ៍សវនកម្មអនុលោមភាពឆ្នាំ២០២២

៥ បញ្ហាប្រឈម និងដំណោះស្រាយ៖ ដំណាក់កាលជួបពិភាក្សាជាមួយសវនដ្ឋានលើរបាយការណ៍សវនកម្មអនុលោមភាពឆ្នាំ២០២២

# ១ ដំណាក់កាលចុះស្វែងយល់សវនដ្ឋាន

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ការកំណត់អំពីបញ្ហាដែលត្រូវសាកសួរ | គួរសិក្សាស្វែងយល់ពីសកម្មភាពរបស់សវនដ្ឋាន ឱ្យបានស៊ីជម្រៅ |
| ២ | ខ្វះបច្ចេកទេសក្នុងការសួរដេញដោល | សវនករគួរសិក្សា និងព្យាយាមអនុវត្តបន្ថែម |
| ៣ | សវនដ្ឋានផ្តល់ឯកសារមិនត្រូវតាមការស្នើសុំ | សវនដ្ឋានគួរផ្តល់នូវឯកសារតាមការស្នើសុំឱ្យបាន ទាន់ពេលវេលាដល់សវនករទទួលបន្ទុក |
| ៤ | ការឆ្លើយតបរបស់សវនដ្ឋានទៅនឹងសំណួររបស់សវនករមិនមានភាពពេញលេញ | សវនដ្ឋានគួរបកស្រាយចម្លើយឱ្យបានពេញលេញ និងចំគោលដៅ |

# ② ដំណាក់កាលរៀបចំផែនការសវនកម្មអនុលោមភាពឆ្នាំ២០២២

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ខ្វះបទពិសោធន៍ក្នុងការរៀបចំផែនការសវនកម្ម | សិក្សាពីការរៀបចំផែនការសវនកម្មរបស់ស្ថាប័នផ្សេងៗ |
| ២ | មិនទាន់យល់ច្បាស់ពីការកំណត់ប្រធានបទ | ពិនិត្យលើសកម្មភាពដែលមានហានិភ័យ និងលក្ខណៈវិនិច្ឆ័យ |

## ៣ ដំណាក់កាលចុះប្រមូលទិន្នន័យ និងព័ត៌មាននៅសវនដ្ឋាន

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
| --- | --- | --- |
| ១ | ខ្វះបទពិសោធន៍ក្នុងការចុះអនុវត្ត | សិក្សា និងពិនិត្យមើលចំណុចខ្វះចន្លោះ និងព្យាយាមកែតម្រូវ |
| ២ | ពិបាកក្នុងការស្នើសុំឯកសារ | ឯកសារដែរត្រូវស្នើសុំគួរបញ្ចូលក្នុងបញ្ជីត្រួតពិនិត្យ |
| ៣ | ទីតាំងដែលសវនដ្ឋានផ្តល់ឱ្យសវនករធ្វើការមានសភាពតូចចង្អៀត | គួរតែមានទីតាំងផ្ទាល់ខ្លួន ដើម្បីឱ្យសវនករងាយ-ស្រួលក្នុងការត្រួតពិនិត្យឯកសារ |
| ៤ | ទីតាំងសវនដ្ឋានមានការជុសជុល | បទបែនតាមស្ថានភាពជាក់ស្តែង |

## ៣ ដំណាក់កាលចុះប្រមូលទិន្នន័យ និងព័ត៌មាននៅសវនដ្ឋាន (ត)

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
| --- | --- | --- |
| ៥ | មន្ត្រីរបស់សវនដ្ឋានមិនបានផ្តល់បទប្បញ្ញត្តិលម្អិតគ្រាប់គ្រាន់ដែលទាក់ទងនឹងការអនុវត្តប្រភពចំណូលរបស់ **ន.គ.ស.**។ | ចូលរួមសហការរបស់ **ន.គ.ស.** ក្នុងការស្វែងរកបទប្បញ្ញត្តិបន្ថែម លើការអនុវត្តចំណូលរួមទាំងបទប្បញ្ញត្តិបានធ្វើបច្ចុប្បន្នភាព និងបទប្បញ្ញត្តិចាស់(ក្រុមប្រឹក្សាជាតិគណនេយ្យ) ដើម្បីផ្ទៀងផ្ទាត់ជាមួយការអនុវត្តចំណូល ដែលជាលក្ខណៈវិនិច្ឆ័យរបស់សវនកម្ម។ |
| ៦ | ពេលចុះសវនកម្ម មិនទាន់មានបុគ្គលទទួលបន្ទុកសម្របសម្រួលការងារសវនកម្មនៅឡើយ | ធ្វើការទាក់ទងផ្ទាល់ជាមួយមន្ត្រីជំនាញពាក់ព័ន្ធតាមប្រធានបទ។ |

## ៣ ដំណាក់កាលចុះប្រមូលទិន្នន័យ និងព័ត៌មាននៅសវនដ្ឋាន (ត)

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ៧ | មានការស្នើសុំផ្លាស់ប្តូរពេលវេលាចុះធ្វើសវនកម្ម (ខុសកាលបរិច្ឆេទក្នុងផែនការសវនកម្ម) | សម្របសម្រួលតាមការស្នើសុំ ប្រកាន់គោលនយោបាយបត់បែន |
| ៨ | ឯកសារមួយចំនួនមិនមែនជាឯកសារផ្លូវការ | ស្នើសុំឯកសារផ្លូវការ |
| ៩ | មិនទាន់យល់ច្បាស់ពីការរៀបចំបញ្ជីត្រួតពិនិត្យ | ខំស្រាវជ្រាវបន្ថែម និងពិនិត្យលើឯកសារពាក់ព័ន្ធផ្សេងៗ |

## ៤ ដំណាក់កាលរៀបចំរបាយការណ៍សវនកម្មអនុលោមភាពឆ្នាំ២០២២

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ភាពខ្វះចន្លោះនៃសំណេរ | សិក្សា និងពិនិត្យមើលចំណុចខ្វះចន្លោះ និងព្យាយាមកែតម្រូវ |
| ២ | ទម្រង់របាយការណ៍សវនកម្មមិនទាន់បានរៀបចំរួចរាល់ | រៀបចំទម្រង់របាយការណ៍សវនកម្មបណ្តើ និងបញ្ចូលលទ្ធផលសវនកម្មបណ្តើរ |
| ៣ | ឯកសារមួយចំនួនមិនទាន់បានទទួលពីសវនដ្ឋាន | បន្តស្នើសុំឯកសារពីសវនដ្ឋានជាច្រើនដង ដើម្បីទទួលបានទិន្នន័យ និងព័ត៌មានសវនកម្ម ហើយឯកសារដែលសវនដ្ឋានមិនបានផ្តល់ឱ្យ សវនករបានដាក់ចូលក្នុងលទ្ធផលសវនកម្ម |

# ដំណាក់កាលជួបពិភាក្សាជាមួយសវនដ្ឋានលើរបាយការណ៍សវនកម្ម អនុលោមភាពឆ្នាំ២០២២

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ការប្រើពាក្យពេចន៍មួយចំនួនមានភាពធួន់ ដែលធ្វើឱ្យសវនដ្ឋានមិនអាចទទួលយកបាន | ក្រោយពីបានប្រជុំគណៈកម្មការចំពោះកិច្ចអំពីការឆ្លើយតបរបស់សវនដ្ឋាន សវនករបានសម្រួលពាក្យពេចន៍ឱ្យមានភាពស្របគ្នា និងទទួលយកបានរវាងសវនករ និងសវនដ្ឋាន។ បន្ថែមពីនេះ សវនករបានពន្យល់អំពីនីតិវិធីនៃការធ្វើសវនកម្ម និងការប្រកាន់ភ្ជាប់នូវក្រមសីលធម៌ក្នុងការជ្រើសរើសលក្ខណៈវិនិច្ឆ័យសវនកម្មដោយមិនលំអៀង។ |
| ២ | សវដ្ឋានឆ្លើយតបលើរបាយការណ៍នៅចុងកាលបរិច្ឆេទដែលធ្វើឱ្យខាតពេលក្នុងការបូកសរុបរបាយការណ៍(ខុសពេលដែលកំណត់ក្នុងផែនការសវនកម្ម) | សវនករត្រូវពន្លឿនការកែតម្រូវរបាយការណ៍ |

# សូមអរគុណ

# THANKS FOR YOUR ATTENTION



អង្គភាពសវនកម្មផ្ទៃក្នុង

INTERNAL AUDIT UNIT




Internal Audit Unit of Non-bank Financial Services Authority

អគារ ១៦៨F ជាន់ទី៩ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ